# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យសពបងស្រីអាខែល នៃក្រុមគ្រួសារបុត្រីមេត្តាករុណា
# ទីវទំពុន ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០
## ផ្លូវនៃសុភមង្គល

**អត្ថបទទី១៖ សាមូអែលទី១ ១៦,១-១៣**

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «គឺម្នាក់នេះហើយ! ចូរចាក់ប្រេងអភិសេកគេចុះ!»។១សម ១៦,១២ខ

**ដំណឹងល្អ៖ ម៉ាកុស ២,២៣-២៨**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្ប័ទ ដើម្បីជាប្រយោជន៍ដល់មនុស្ស ព្រះអង្គមិនបានបង្កើតមនុស្ស ដើម្បីឲ្យបម្រើថ្ងៃសប្ប័ទឡើយ។ មក ២,២៧

បងប្អូនជាទីស្រឡាញ់!

តាមប្រពៃណីនៅក្នុងគ្រីស្តសាសនា យើងត្រូវតែអធិដ្ឋានទូលអង្វរសន្តយ៉ូសែប ឲ្យយើងស្លាប់នៅក្នុងរបៀបស្រួលនិងល្អ។ បងស្រីអាខែល ប្រហែលធ្លាប់អធិដ្ឋានដល់សន្តយ៉ូសែបច្រើនដង ដោយសារគាត់ទទួលមរណភាពយ៉ាងស្រួលបំផុត ដូចមនុស្សកំពុងដេកលក់។ បងស្រីនៅក្នុងដៃរបស់សន្តយ៉ូសែប ជាពិសេសនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ និងព្រះមាតារបស់ព្រះជាម្ចាស់។ គ្រួសារបុត្រីមេត្តាករុណា មានទីតាំងនៅទីក្រុងប៉ារីស ដែលមានរូបព្រះនាងម៉ារីមួយពិសេសដែលបងស្រីធ្លាប់ចែកជាមេដាយតូចៗ។ មេដាយនេះ ជាមេដាយមួយដែលណែនាំឲ្យមនុស្សយ៉ាងច្រើនមានសេចក្តីសុខ នៅពេលគេអធិដ្ឋានថា "**ឱព្រះនាងម៉ារី ដែលគ្មានជំពាក់បាប សូមអធិដ្ឋានដល់យើងដែលកំពុងទីពឹងលើព្រះនាង**"។ ជាង១០០ឆ្នាំហើយ មានគ្រីស្តបរិស័ទជាច្រើនបានទៅអធិដ្ឋាន និងចូលរួមអភិបូជានៅកន្លែងព្រះនាងម៉ារីនោះ និងទទួលការអស្ចារ្យនៅក្នុងជីវិត។

ខ្ញុំជឿថា បងស្រីប៉ុន្មានដងដែលបានអធិដ្ឋានទៅព្រះនាងម៉ារី "**ឱព្រះនាងម៉ារីដែលគ្មានជំពាក់បាប សូមអធិដ្ឋានដល់យើងដោយសារយើងទីពឹងលើព្រះនាង**"។ បងស្រីមកពីក្រុមគ្រួសារបុត្រីមេត្តាករុណា ជាក្រុមគ្រួសារដែលបង្កើតរួមជាមួយសន្ត វ៉ាំងសង់ដឺប៉ូល នៅសតវត្សរ៍ទី១៧។ សន្ត វ៉ាំងសង់ដឺប៉ូល ជាបូជាចារ្យម្នាក់ដែលបានធ្វើការជាមួយអ្នកក្រីក្រ អ្នកជំងឺ ប្រមូលអ្នកមានជាពិសេសម្ចាស់ក្សត្រីយ៍ដែលមានលុយច្រើន ដើម្បីយកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ។ សន្ត វ៉ាំងសង់ដឺប៉ូល ធ្លាប់និយាយថា "**សេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ណែនាំឲ្យ**

**យើងច្នៃប្រឌិតអត់មានព្រំដែន**"។ ពេលយើងមានសេចក្ដីស្រឡាញ់នៅក្នុងដួងចិត្ត យើងមានសមត្ថភាពដើម្បីមានគំនិតថ្មីៗគ្រប់ពេលវេលា ដែលគ្មានព្រំដែននៅក្នុងសេចក្ដីស្រឡាញ់។ ជីវិតរបស់បងស្រីដែលជាបងស្រីអស់៥០ឆ្នាំ យើងមើលឃើញបងស្រីបានអនុវត្តសេចក្ដីស្រឡាញ់ដែលគ្មានព្រំដែន ដោយចាប់ផ្ដើមជីវិតនៅប្រទេសភីលីពីន ដែលគាត់ទទួលសាលាដែលជាកន្លែងមានជនជាតិដើម ក្រោយមកគាត់ទៅប្រទេសថៃ ធ្វើការនៅស្ថានទូតជាមួយសន្តអសនៈ។ ជាពិសេស បងស្រីបានធ្វើការនៅជំរំដែលមានជនភៀសខ្លួនមកពីប្រទេសកម្ពុជា គាត់ធ្វើការជាមួយក្មេងពិការ ជាមួយអ្នកជំងឺអេដស៍ ធ្វើការជាមួយចាស់ជរា ក្រោយមកបងស្រីទៅប្រទេសឡាវ។ នៅប្រទេសឡាវ គាត់បានចាប់ផ្ដើមបេសកកម្មដំបូងនៃក្រុមគ្រួសារបុត្រីមេត្តាករុណានៅប្រទេសនោះ ហើយគាត់ទៅប៉ៃលិន ពីប៉ៃលិនមកដល់តាកែវ។ ទោះបីគាត់ចាស់ហើយ ប៉ុន្តែគាត់បានសុខចិត្តទៅធ្វើការនៅខេត្តតាកែវ ដើម្បីចែករំលែកសេចក្ដីស្រឡាញ់ដែលគាត់ទទួលពីព្រះជាម្ចាស់ ដល់អ្នកតូចតាចអស់ពីសមត្ថភាព។

សន្ត វាំងសង់ដឺប៉ូល ធ្លាប់និយាយថា "**កម្មករ៣នាក់ធ្វើការច្រើនជាងកម្មករ១០នាក់ លុះត្រាតែមានព្រះជាម្ចាស់ដែលគង់នៅ**" យើងឃើញបងស្រីមានតែ៣នាក់ ប៉ុន្តែធ្វើការបានច្រើនណាស់។ ថ្ងៃនេះ យើងមានបងប្អូនដែលមកពីតាកែវយ៉ាងច្រើន ដោយសារគេបានទទួលសេចក្ដីស្រឡាញ់និងសាក្សីភាពពីបងស្រីយ៉ាងច្រើន នៅក្នុងប៉ុន្មានឆ្នាំកន្លងមក។ នៅពេលយើងមានព្រះជាម្ចាស់ដែលគង់នៅ កម្មករ៣នាក់មានកម្លាំង មានសមត្ថភាព មានសេចក្ដីស្រឡាញ់ច្រើនជាងកម្មករ១០នាក់។ បងស្រី បានយកចិត្តទុកដាក់ជាមួយមនុស្សដែលមានបញ្ហាខួរក្បាលនៅតាមភូមិនានា យកចិត្តទុកដាក់ទៅសួរសុខទុក្ខដល់អ្នកជាប់នៅមន្ទីរឃុំឃាំងខេត្តតាកែវរាល់ខែ ដើម្បីអប់រំ ដើម្បីលើកទឹកចិត្ត ដើម្បីធ្វើដំណើរជាមួយគេ។ សន្ត វាំងសង់ដឺប៉ូល ធ្លាប់និយាយទៀតថា "**ស្ថានបរមសុខនៅលើផែនដីនេះមានហើយ ដូចនៅស្ថានលើលុះត្រាតែយើងចេះស្រឡាញ់គ្នាទៅវិញទៅមក នៅពេលយើងបង្កើតសេចក្ដីស្រឡាញ់ យើងអាចមើលឃើញស្ថានបរមសុខនៅលើផែនដីយើងបាន**"។ បងស្រីអាឌែលពូកែញញឹម ស្នាមញញឹមរបស់បងស្រី របៀបដែលបងស្រីយកចិត្តទុកដាក់ជាមួយបងប្អូនឯទៀតៗ ជាពិសេសអ្នកតូចតាច របៀបដែលបងស្រីណែនាំឲ្យមានជីវិតជាក្រុមគ្រួសារ ជាបងប្អូនគ្នានៅក្នុងក្រុមបងស្រី បានណែនាំឲ្យយើងមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលព្រះយេស៊ូចង់បង្កើតលើផែនដីយើងជាប្រចាំ ជាពិសេសនៅប្រទេសកម្ពុជា។ ផ្លូវនៃសុភមង្គលដ៏ពិតប្រាកដ បីដូចជាពន្លឺមួយដែលណែនាំឲ្យយើងមើលឃើញជីវិតបងស្រីផង ណែនាំឲ្យយើងមើលឃើញរបៀបដែលយើងជាគ្រីស្តបរិស័ទ ត្រូវការយកចិត្តទុកដាក់ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់លើផែនដីនេះផង។

ឥរិយាបថ អាកប្បកិរិយា ចរិតរបស់យើងជាគ្រីស្តបរិស័ទ ផ្លូវនៃសុភមង្គលយើងបានស្តាប់ថា "**អ្នកណាដែលដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកណាមានចិត្តបរិសុទ្ធ អ្នកណាមានចិត្តស្លូតបូត អ្នកនោះមានសុភមង្គលហើយ**"។ នៅពេលយើងឃើញអ្នកក្រខ្សត់ នឹកឃើញដល់បងស្រីជារៀងរាល់ឆ្នាំប្រកាសថា "**ខ្ញុំសុខចិត្តធ្វើជាអ្នកក្រីក្រ ដើម្បីភ្ជាប់ជាមួយបងប្អូន ជាពិសេសជាមួយអ្នកតូចតាច ដោយលះបង់ចោលអ្វីៗទាំងអស់ដែលមាននៅក្នុងចិត្ត ដើម្បីរស់នៅតាមព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់**"។ បងស្រីមានពាក្យសច្ចាមួយទៀតគឺ "**ព្រហ្មចារី**" នេះជាចិត្តបរិសុទ្ធរបស់បងស្រី ដែលណែនាំឲ្យបងស្រីភ្ជាប់ជាអង្គតែមួយទាំងជាមួយព្រះសហាគមន៍ ទាំងជាមួយអស់បងប្អូនដែលបងស្រីបម្រើជាប្រចាំ។ ពាក្យសច្ចាមួយទៀតគឺ "**ស្តាប់បង្គាប់**" ពេលយើងស្តាប់បង្គាប់ យើងត្រូវការមានចិត្តស្លូតបូត បងស្រីអាចទៅមុខអស់ពីសមត្ថភាពនៅក្នុងចិត្តស្លូតបូត។

យើងមានសកម្មភាព៣ ដែលយើងស្តាប់នៅក្នុងផ្លូវនៃសុភមង្គល គឺកសាងសុខសន្តិភាព មានចិត្តមេត្តាករុណា និងស្រេកឃ្លានយុត្តិធម៌។ នេះជាជីវិតរបស់បងស្រី ទាំងនៅប្រទេសថៃ ឡាវ កម្ពុជា ធ្វើការជាមួយអ្នកពិការ ធ្វើការជាមួយកូនក្មេងអនាថា ធ្វើការជាមួយជនភៀសខ្លួន ធ្វើការជាមួយអ្នកជាប់នៅមន្ទីរឃុំឃាំង ធ្វើការជាមួយចាស់ជរា ដើម្បីកសាងសុខសន្តិភាព ដើម្បីចែករំលែកមេត្តាករុណា ដើម្បីឆ្លើយតបយុត្តិធម៌ដែលយើងត្រូវការនៅក្នុងជីវិតរបស់យើង។ ពាក្យចុងក្រោយរបស់សន្ត វាំងសង់ដឺប៉ូល គាត់ថា "ខ្ញុំសោកស្តាយរឿងតែមួយ គឺខ្ញុំអត់បានស្រឡាញ់គេល្មមទេ"។ នៅពេលគាត់ឆ្លើយដូចនេះ ជីវិតរបស់យើងកុំគិតថាមានអ្វីល្មម សេចក្តីស្រឡាញ់របស់យើងអត់ដែលល្មមទេ។ ដូចគ្នាដែរ ខ្ញុំគិតថាបងស្រី អាឌែល បានបង្រៀនឲ្យយើងចេះស្រឡាញ់ថែមទៀត។

ខ្ញុំអរគុណបងស្រីអាឌែល ដែលយកចិត្តទុកដាក់នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងសញ្ញាតូចតាចដែលជាគំរូសម្រាប់យើង ដើម្បីបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់។ បងស្រីបានឆ្លងកាត់ទុក្ខលំបាកយ៉ាងច្រើន ក៏ប៉ុន្តែនៅក្នុងគ្រប់ទុក្ខលំបាក គាត់បានយកចិត្តទុកដាក់ដើម្បីទៅមុខ ជាពិសេសដើម្បីការពារថែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកផង ជាមួយបងប្អូនផង ជាមួយបងស្រីផង ដោយដឹងថាអ្វីដែលស្ថិតស្ថេរ គឺទំនាក់ទំនងជាបងប្អូនជារៀងរហូត។ នៅពេលនេះបងស្រី អាឌែល ទៅជួបព្រះនាងម៉ារី ទៅជួបអ្នកក្រីក្រដែលបងស្រីបានបម្រើអស់ពីដួងចិត្ត អស់មួយជីវិតរបស់គាត់។ យើងដឹងថា នៅស្ថានបរមសុខអ្នកក្រីក្រទៅជាព្រះអម្ចាស់ មានអ្នកក្រីក្រទាំងអស់ដែលស្វាគមន៍បងស្រីនៅក្នុងអំណរ និងសេចក្តីសុខសាន្តដែលមកពីព្រះជាម្ចាស់។ ពិតមែន អ្នកដែលដាក់ខ្លួនជាអ្នកក្រខ្សត់ ពោរពេញដោយសុភមង្គលដោយសារព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅជាមរតករបស់ពួកគេ។

យើងអធិដ្ឋាន ដើម្បីឲ្យយើងទាំងអស់គ្នាទទួលព្រះពរ នៅក្នុងសេចក្តីសុខរបស់ព្រះជាម្ចាស់ ដោយការពារថែរក្សាសេចក្តីសង្ឃឹមទៅលើព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ របៀបដែលបងស្រីទទួលមរណភាព ណែនាំឲ្យយើងត្រៀមជានិច្ច "**បពិត្រព្រះនាងម៉ារី ដែលគ្មានជំពាក់បាប សូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់សម្រាប់យើង យើងទីពឹងលើព្រះនាង**"។ អាម៉ែន៕